ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
លេខាធិការដ្ឋានរដ្ឋបាលសរុប
លេខ:....................របក

# របាយការណ៍ស្តីពី
# កិច្ចប្រជុំឆមាសទី១ ឆ្នាំ២០១៩
# នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

កិច្ចប្រជុំឆមាសទី១ នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលហៅកាត់ថា គ.ជ.ប.ជ បានប្រព្រឹត្តទៅ កាលពីថ្ងៃអង្គារ ៧រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ០៨.៣០ នាទី ព្រឹក នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ ជារដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងថ្នាក់ដឹកនាំជាន់ខ្ពស់ដទៃទៀត ពីក្រសួង ស្ថាប័ន អង្គភាពជាសមាជិកគណៈកម្មាធិការជាតិ សរុបចំនួន ៤៤ រូប (ស្រី ១៨រូប) ។

របៀបវារៈ នៃកិច្ចប្រជុំ គឺផ្តោតលើលទ្ធផលនៃសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលបានអនុវត្តដោយ គណៈកម្មាធិការ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងរយៈពេល ៦ខែដើមឆ្នាំ និងធ្វើការវាយតម្លៃលើចំណុចខ្វះខាត ភាពប្រឈម ដែលត្រូវលើកទិសដៅដោះស្រាយ ទៅឆមាសទី២ទៀត ។ ជាលទ្ធផលមានដូចខាងក្រោម៖

បន្ទាប់ពីបានស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិក នៃគណៈកម្មាធិការជាតិ ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំឆមាសទី១ នេះ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន គ.ជ.ប.ជ** បានជម្រាបជូនសមាជិក សមាជិកាអំពីស្ថានភាពទូទៅ ពាក់ព័ន្ធនឹងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការការពារសុវត្ថិភាពប្រជាពលរដ្ឋ និងស្ថេរភាពនយោបាយ និងសេដ្ឋកិច្ចជាតិ ។ របៀបវារៈនៃកិច្ចប្រជុំ គឺផ្តោតលើរបាយការណ៍លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងឆមាសទី១ និងបញ្ហាផ្សេងៗ ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស **សម្តេច** បានស្នើឲ្យសមាជិក សមាជិកា នៃអង្គប្រជុំផ្តល់មតិយោបល់លើរបាយការណ៍នេះ អំពីសកម្មភាពការងាររបស់ខ្លួន ដែលត្រូវកែសម្រួល ឬបន្ថែមលើចំណុចដែលខ្វះខាត។ **សម្តេចក្រឡាហោម** ក៏ចាប់អារម្មណ៍ផងដែរ អំពីការផ្តល់ចំណាត់ថ្នាក់លេខ២ ក្រោមការឃ្លាំមើលរបស់សហរដ្ឋអាមេរិក សម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ដោយត្រូវរកឲ្យឃើញថា តើមានហេតុផលអវិជ្ជមានអ្វីខ្លះ ដែលនាំឲ្យមានការផ្តល់ចំណាត់ថ្នាក់បែបនេះ? និងថាតើត្រូវកែលម្អស្ថានភាពដូចម្តេច?

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានធ្វើសេចក្តីរាយការណ៍សង្ខេបអំពីរបាយការណ៍ឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ២០១៩ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកឡើង អំពីកំណត់សម្គាល់មួយចំនួន មានជាអាទិ៍គឺៈ លទ្ធផលការងារ បានប្រសើរជាងឆ្នាំមុន បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នា ជាពិសេស លើការងារកិច្ចសហការ បង្ការទប់ស្កាត់ ការអនុវត្តច្បាប់ ទាំងការបង្រ្កាប សង្គ្រោះ ការផ្តន្ទាទោស និងកិច្ចការពារជនរងគ្រោះជាដើម ។ តែទន្ទឹមនឹងនោះ បញ្ហាចំណាកស្រុកដោយប្រថុយប្រថាន មិនមានការធានាសុវត្ថិភាពផ្នែកច្បាប់ ជាពិសេស ទៅប្រទេសថៃ ដែលមានពលកររហូតដល់ទៅជាងមួយលាននាក់ នៅតែជាកង្វល់ដែលត្រូវបន្តដោះស្រាយ ។ ក្នុងនោះ ទោះបីជាមានការផ្តល់ភាពស្របច្បាប់ក្នុងឆ្នាំ២០១៧-២០១៨ កន្លងទៅ តែក៏នៅប្រឈមនឹងការបញ្ចប់សុពលភាព និងការប្រើប្រាស់ឯកសារមិនប្រក្រតីក្លែងបន្លំ ឬខុសទិន្នន័យជាដើម ដែលមិនអាចធានាសុវត្ថិភាព និងផលប្រយោជន៍ស្របច្បាប់បាន ហើយពលករជាច្រើន នៅតែរងគ្រោះ ។

មួយវិញទៀត របាយការណ៍បានបង្ហាញថា ជនរងគ្រោះជាអនីតិជន មានចំនួនច្រើនលើសលុបគួរឲ្យបារម្ភ ដែលត្រូវបង្កើនការយកចិត្តទុកដាក់មិនអាចមើលរំលងបាន ។

**ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន** អគ្គស្នងការនគរបាលជាតិប្រធានក្រុមការងារអនុវត្តច្បាប់ បានសម្តែងនូវការឯកភាព និងគាំទ្រលើរបាយការណ៍ឆមាសទី១ ដែលអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ប្រមូលចងក្រងបូកសរុប និងវាយតម្លៃ ព្រមទាំងគាំទ្រមតិដឹកនាំរបស់សម្តេចក្រឡាហោម ប្រធាន គ.ជ.ប.ជ ។ ឯកឧត្តម បានសម្តែងអារម្មណ៍អាក់អន់ចិត្ត លើការផ្តល់ចំណាត់ថ្នាក់លេខ២ ក្រោមការឃ្លាំមើល មកលើកម្ពុជា សម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់សហរដ្ឋអាមេរិក ដែលបង្ហាញពីការសម្រេចចិត្តដោយលម្អៀង បែបនយោបាយជាឯកតោភាគី របស់ខ្លួន ។ ឯកឧត្តម បានស្នើតំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជួយបកស្រាយបំភ្លឺអំពីករណីនេះ។

**ឯកឧត្តម ស៊ា កុសល** រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានប្រសាសន៍បំភ្លឺពាក់ព័ន្ធការដាក់ចំណាត់ថ្នាក់លេខ២ លើការងារប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា របស់សហរដ្ឋអាមេរិក។ ពាក់ព័ន្ធនឹងរបាយការណ៍ ឯកឧត្តមបានកោតសរសើរចំពោះ លទ្ធផលដែលទទួលបាន តែនៅមានចំណុចមិនច្បាស់លាស់ ទាមទារឲ្យមានការបកស្រាយពន្យល់ ពាក់ព័ន្ធ នឹងទិន្នន័យនៃចំណាកស្រុក ដែលជាការតាមដានរបស់នគរបាលនៅមូលដ្ឋាន ។

**លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានលើកយកអត្ថបទដែលសហរដ្ឋអាមេរិក បញ្ជាក់ថាជាហេតុផល នៃការវាយតម្លៃ និងចាត់ចំណាត់ថ្នាក់សហរដ្ឋអាមេរិកលើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ២ ក្នុងការឃ្លាំមើល។ ការកត់សម្គាល់របស់សហរដ្ឋអាមេរិក គឺគេបានទទួលស្គាល់ថា ការប្រឹងប្រែង

របស់រាជរដ្ឋាភិបាលកម្ពុជាលើការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សមានការរីកចម្រើន តែនៅមានចំណុចខ្វះខាតមួយចំនួនក្នុងប្រតិបត្តិការ ។ អាស្រ័យដោយរបាយការណ៍ដែលត្រូវធ្វើការវាយតម្លៃ មានកំណត់ពេលខុសគ្នាពី គណៈកម្មាធិការជាតិ នាំឲ្យបាត់កិច្ចប្រឹងប្រែងមួយចំនួនមិនត្រូវបានរាប់បញ្ចូល រីឯចំណុចដែលធ្វើឲ្យប្រតិបត្តិករ មិនសប្បាយចិត្ត គឺការវាយតម្លៃនេះ បានគួបផ្សំនឹងនិន្នាការនយោបាយ ។ ចំពោះទិន្នន័យតាមដានបច្ចុប្បន្នភាពពលករចំណាកស្រុក ដែលមានជាមធ្យមប្រចាំខែ ប្រមាណ ៣៦ម៉ឺននាក់ មិនមានន័យថាជាចំនួនពលករដែលចាកចេញបន្ថែមជារៀងរាល់ខែនោះទេ តែមានន័យថា ចំនួននេះ មិនមានវត្តមានក្នុងមូលដ្ឋាន តាមខែនីមួយៗ ដែលអាចមានអ្នកត្រឡប់មកហើយ ចាកចេញទៅវិញ ។

**លោកជំទាវ វេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ប្រធានក្រុមការងារសហប្រតិបត្តិការអន្តរជាតិ បានជម្រាបជូន នូវការងារពាក់ព័ន្ធនឹងការធ្វើសេចក្តីព្រាងច្បាប់ស្តីពីការពពោះជំនួសដែលមិនអនុញ្ញាតឲ្យពាក់ព័ន្ធនឹងជនបរទេសនោះទេ ហើយកន្លងមកសេចក្តីព្រាងច្បាប់ បានអនុញ្ញាតឲ្យតែជនជាតិខ្មែរដែលជាករណីមនុស្សធម៌ មិនគិតផលប្រយោជន៍ ហើយក៏ត្រូវមានលក្ខណ្ឌជាច្រើន ទៀតដែលត្រូវពិនិត្យមុននឹងអនុញ្ញាតិឲ្យពពោះជំនួស ដូចជាត្រូវមានការបញ្ជាក់ពីជំនាញសុខាភិបាលអំពីភាពអសមត្ថភាពនៃគូស្វាមីភរិយា ក្នុងការបង្កកំណើត លក្ខ័ណ្ឌនៃការជ្រើសរើសអ្នកពពោះ ។ល។ លោកជំទាវ បានគោរពស្នើសុំការដឹកនាំពីសម្តេច ក៏ដូចជាប្រមុខរាជរដ្ឋាភិបាល ថាតើត្រូវកំណត់បែបណា ចំពោះសេចក្តីព្រាងច្បាប់នេះ ។ លោកជំទាវ បានចាត់ទុកការវាយតម្លៃរបស់សហរដ្ឋអាមេរិក ថាជារឿងអយុត្តិធម៌សម្រាប់កម្ពុជា ព្រោះជាការវាយតម្លៃតាមទំនោរទៅរកបញ្ហានយោបាយ ។

**ឯកឧត្តម នឹម ថូត** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានចូលរួមមតិពាក់ព័ន្ធនឹងបញ្ហាពពោះជំនួសនៅកម្ពុជា ដែលពាក់ព័ន្ធនឹងការសុំកូនជាលក្ខណៈអន្តរជាតិ និងការផ្តល់សញ្ជាតិឲ្យទារក ជាពិសេសកូនដែលកើតនៅក្នុងប្រទេសគោលដៅ។ ឯកឧត្តម ក៏បានបញ្ជាក់អំពីសេចក្តីត្រូវការមណ្ឌលសំចតនៅតាមបណ្តាច្រកទ្វារព្រំដែន និងបានស្នើសុំឲ្យមានការសាងសង់បន្ថែមតាមបណ្តាច្រកធំៗដូចជា បាត់ដំបង កោះកុង ប៉ៃលិន និងស្វាយរៀងជាដើម។

**ឯកឧត្តម វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធានក្រុមការងារការពារជនរងគ្រោះ បានជម្រាបជូនសម្តេច ប្រធាន គណៈកម្មាធិការជាតិ និងសមាជិក នៃអង្គប្រជុំ អំពីគម្រោងសាងសង់ មណ្ឌលសំចត ដែលជាជំនួយរដ្ឋាភិបាលថៃ ថានឹងអាចចាប់ផ្តើម នៅខែតុលាឆ្នាំ២០១៩នេះ ។ គម្រោងនេះ មានការយឺតយ៉ាវ អស់រយៈពេលជាង១០ឆ្នាំមកហើយ អាស្រ័យដោយមានភាពមិនចុះសម្រុងខ្លះ ពាក់ព័ន្ធនឹងលក្ខណ្ឌនៃការផ្តល់ជំនួយ ផ្សាភ្ជាប់នឹងផលប្រយោជន៍ នៃការនាំទំនិញចូលដោយរួចពន្ធ ។

ជាទីបញ្ចប់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានផ្តល់អនុសាសន៍ដឹកនាំបន្ថែមទៀត ដើម្បីធ្វើឲ្យរបាយការណ៍កាន់តែពេញលេញ និង កំណត់បន្ថែមទិសដៅមួយចំនួន ដូចខាងក្រោម៖

- បណ្ដាអន្តរក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គប្បីផ្ញើរបាយការណ៍មកអគ្គលេខាធិការដ្ឋាន ឲ្យបានទាន់ពេលវេលាកំណត់ ដើម្បីងាយស្រួលធ្វើការបូកសរុប និងផ្សព្វផ្សាយទាន់ពេលវេលា ។

-ក្រុមការងារកិច្ចការយុត្តិធម៌ និងក្រុមការងារទេសន្តរប្រវេសន៍ គប្បីពង្រឹងការដឹកនាំក្រុមការងារ ដោយរៀបចំប្រជុំឲ្យបានទៀងទាត់ ។

-គ្រប់ក្រុមការងារ ដែលមានក្រសួងស្ថាប័ន មន្ទីរអង្គភាពជាសមាជិកគប្បីខិតខំប្រឹងប្រែងធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យបានល្អបន្តទៀត ដើម្បីប្រជាជន និងប្រទេសជាតិយើង ។ ចំពោះការដាក់ចំណាត់ថ្នាក់ដោយមានទំនោរទៅបញ្ហានយោបាយ គឺជារឿងរបស់គេ តែយើងនៅតែបន្តការងារ ជារឿងរបស់យើង ដើម្បីលើកកម្ពស់ការគោរពសិទ្ធិមនុស្ស។

-ចំពោះការសាងសង់មណ្ឌលទទួលពលករ គួរគិតទៅច្រកទ្វារអន្តរជាតិដូង ខេត្តបាត់ដំបង ដែលមានការបញ្ជូនពលករត្រឡប់មកពីអាជ្ញាធរបរទេសច្រើន បន្ទាប់ពីច្រកទ្វារអន្តរជាតិប៉ោយប៉ែត ។ **សម្ដេច** បានប្រគល់ភារកិច្ច ជូនអគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីធ្វើការសិក្សា និងលើកគម្រោងសាងសង់មណ្ឌលនេះ ។

-**សម្ដេច** បានស្នើឲ្យមានការពិគ្រោះយោបល់ ដឹកនាំដោយក្រសួងយុត្តិធម៌ ចំពោះការបង្កើតបទដ្ឋានច្បាប់ស្ដីពីការបង្កក និងដកហូតទ្រព្យសម្បត្តិ ដែលបានមកពីបទល្មើស រួមទាំង ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន និងជំនួញឈើខុសច្បាប់ជាដើម ។

-ទន្ទឹមនឹងនោះ **សម្ដេច** បានស្នើឲ្យអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀបចំការពិភាក្សាពិគ្រោះយោបល់បន្ថែមទៀត ក្នុងចំណោមស្ថាប័នពាក់ព័ន្ធ អំពីវិសាលភាពនៃអំពើពោះជំនួស និងសិក្សាអំពីលទ្ធភាព ថ្លឹងថ្លែងអំពីផលប៉ះពាល់ និងផលប្រយោជន៍ និងទោសទណ្ឌជាដើម ដើម្បីកែលម្អសេចក្ដីព្រាងច្បាប់ឲ្យកាន់តែមានភាពលម្អិតគ្រប់ជ្រុងជ្រោយ ។

កិច្ចប្រជុំបានបញ្ចប់ដោយជោគជ័យ ក្រោមបរិយាកាសរីករាយ ឯកភាព និងស្និទ្ធស្នាល ។

ថ្ងៃពុធ ៨រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ត្រី.សៅ ស៊ីនួន

29/07/19